ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ០២ ស.ក.ត.

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី**

នៅព្រឹកថ្ងៃសុក្រ ៥កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង៨ និង៣០នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

**១-សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣។**

**២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត។**

**៣-បញ្ហាផ្សេងៗ៖** សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើ «កិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត»។

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

**១-សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣**

សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣ ត្រូវបានរៀបចំឡើងបន្តពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៤-២០១៨ ដែលត្រូវបានចប់អាណត្តិកាលនាចុងឆ្នាំ២០១៨ ក្នុងនីតិកាលទី៥ នៃរដ្ឋសភា កន្លងទៅ។ ផ.យ.អ.ជ. ២០១៩-២០២៣ មានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយអាទិភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០។

ផ.យ.អ.ជ. ២០១៩-២០២៣ ត្រូវបានតាក់តែងឡើងក្នុងគោលបំណងសំខាន់៣បី គឺ៖ (ទី១). ដើម្បីវាយតម្លៃអំពីលទ្ធផលរួមនិងបញ្ហាប្រឈមចម្បងៗ ដែលបានកើតមានឡើងនៅក្នុងការអនុវត្តផ.យ.អ.ជ. ២០១៤-២០១៨ (ទី២). ដើម្បីកំណត់នូវបណ្តាវិធានការគោលនយោបាយនានាដល់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ សម្រាប់ការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ដើម្បីស្ថិរភាពកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ក៏ដូចជាក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ និង (ទី៣). ដើម្បីជាក្របខណ្ឌប្រព័ន្ធមួយសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំនៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ របស់ក្រសួងស្ថាប័ននានា។

សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣ មាន ៧ជំពូក រួមមាន៖

**ជំពូកទី១៖ សេចក្តីផ្តើម**

បង្ហាញអំពីប្រវត្តិនិងទិដ្ឋភាពរួមនៃការវិវត្តនិងជោគជ័យក្នុងការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលដៅអភិវឌ្ឍសហសវត្សរ៍កម្ពុជា ផ្សារភ្ជាប់ទៅនឹងប្រវត្តិនៃការរៀបចំផែនការអភិវឌ្ឍន៍ជាតិ។

**ជំពូកទី២៖ សមិទ្ធផលនិងបញ្ហាប្រឈមក្នុងការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨**

បង្ហាញអំពីសមិទ្ធផលជារួមនៃការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨ និងបញ្ហាប្រឈមនានាដែលបានជួបប្រទះក្នុងអំឡុងពេលនៃការអនុវត្តផែនការនេះ។

**ជំពូកទី៣៖ ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ ផ.យ.អ.ជ. ២០១៩-២០២៣**

បង្ហាញអំពីការវិភាគនៃស្ថានភាពរួមនៃដំណើរវិវត្តរបស់ម៉ាក្រូសេដ្ឋកិច្ច និងដំណើរការនៃការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនៅក្នុងសេដ្ឋកិច្ចកម្ពុជា ដោយរំលេចឡើងអំពីរចនាសម្ព័ន្ធនៃផលិតផលក្នុងស្រុកសរុប ស្ថានភាពសារពើពន្ធនិងអតិផរណា ភាពបើកចំហរនៃសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ជញ្ជីងពាណិជ្ជកម្ម ព្រមទាំងភាពក្រីក្រ និងភាពមានការងារធ្វើ។

**ជំពូកទី៤៖ គោលនយោបាយនិងសកម្មភាពអាទិភាព ២០១៩-២០២៣**

បង្ហាញអំពីសកម្មភាព កម្មវិធី និងគម្រោងនានាដើម្បីអនុវត្តវិស័យអាទិភាពជាយុទ្ធសាស្ត្រទាំងបួនរួមមាន មនុស្ស ផ្លូវ ភ្លើង និងទឹក និងអនុវត្តគោលនយោបាយគន្លឹះនិងអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា ដោយត្រូវបានបែងចែកទៅតាមវិស័យនិងតាមការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននីមួយៗ ស្របតាមទម្រង់របស់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលផ្តោតលើ៖ ស្នូលរបស់ចតុកោណ ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច ចតុកោណទី១ ស្តីពីការអភិវឌ្ឍធនធានមនុស្ស ចតុកោណទី២ ស្តីពីការធ្វើពិពិធកម្មសេដ្ឋកិច្ច ចតុកោណទី៣ ស្តីពីការអភិវឌ្ឍវិស័យឯកជននិងការងារ និងចតុកោណទី៤ ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន។

**ជំពូកទី៥៖ ធនធាននិងការកំណត់កម្មវិធីចំណាយ**

តម្លៃប៉ាន់ស្មានសរុបនៃតម្រូវការធនធានវិនិយោគសម្រាប់អនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ មានចំនួន ៥៧,៧ប៊ីលានដុល្លាអាមេរិក សមមូល ២៣៦ ៦៦១ ប៊ីលានរៀល ក្នុងនោះវិនិយោគមូលធននៃវិស័យឯកជនមានចំនួន ៧៥% និងវិនិយោគមូលធននៃវិស័យសាធារណៈមានចំនួន ២៥%។

**ជំពូកទី៦៖ ការតាមដាន ត្រួតពិនិត្យនិងការវាយតម្លៃ**

បង្ហាញអំពីក្របខណ្ឌនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដោយផ្អែកលើមូលដ្ឋានលទ្ធផលនៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣។ បញ្ជីសូចនាករ ត្រូវបានធ្វើការកែសម្រួល ដោយបានបញ្ចូលនូវសូចនាករស្នូលរបស់ជាតិ និង សូចនាករកម្រិតលទ្ធផលនិងកម្រិតឥទ្ធិពលពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា បែងចែកតាមវិស័យអាទិភាពចំនួន៤។ ក្រសួងផែនការគឺជាសេនាធិការរបស់រាជរដ្ឋាភិបាលដោយសម្របសម្រួលជាមួយក្រសួង ស្ថាប័នលើការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ ផ.យ.អ.ជ. ២០១៩-២០២៣ នេះ។

**ជំពូកទី៧៖ សេចក្តីសន្និដ្ឋាន**

តាមរយៈការអនុវត្តប្រកបដោយជោគជ័យនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ បានជំរុញឱ្យកម្ពុជាវិវត្តខ្លួនទៅជាប្រទេសមួយដែលមានសក្តានុពលសេដ្ឋកិច្ច និងជាប្រទេសគោលដៅវិនិយោគពីបរទេស ហេតុឈានជាប្រទេសដែលមានចំណូលមធ្យម

កម្រិតទាប ក៏ដូចជាបន្តសម្រេចបាននូវវឌ្ឍនភាពសំខាន់ៗជាច្រើនលើគ្រប់វិស័យ។ សម្រាប់ការអភិវឌ្ឍប្រទេសក្នុងដំណាក់កាល ផ.យ.អ.ជ. ២០១៩-២០២៣ រាជរដ្ឋាភិបាលកម្ពុជាបន្តប្តេជ្ញាអនុវត្តការងារតាមអភិក្រម ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ ដើម្បីឈានទៅសម្រេចឱ្យបាននូវវឌ្ឍនភាពថ្មីៗបន្ថែមទៀត។

**២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត**

សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត មានគោលបំណងផ្តល់ឱកាស និងគាំទ្រឱ្យប្រជាជនគ្រប់រូបទទួលបានការសិក្សាតាមគ្រប់រូបភាព និងប្រើប្រាស់ចំណេះដឹងតាមជំនាញដែលទទួលបានដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ និងប្រាក់ចំណូល ស្របតាមយុគសម័យបច្ចេកវិទ្យាព័ត៌មាន និងសង្គមពុទ្ធិ។

ការសិក្សាពេញមួយជីវិត ជាដំណើរការរៀនសូត្រទាំងនៅក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ តាំងពីចាប់កំណើតរហូតដល់វ័យជរា ដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទា ឱ្យក្លាយជាពលរដ្ឋល្អ និងចេះរួមរស់ជាមួយគ្នាប្រកបដោយសុខដុមនៅក្នុងសង្គម។ ការសិក្សាពេញមួយជីវិត សង្កត់ធ្ងន់លើបំណិនបច្ចេកទេសវិជ្ជាជីវៈ បំណិនអាជីព និងបំណិនអប្បវត្ត ដែលអ្នកសិក្សាអាចសិក្សានៅគ្រប់ពេលវេលា គ្រប់ទីកន្លែង គ្រប់មធ្យោបាយ ជាពិសេសប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់គាំទ្រសកម្មភាពសិក្សា។

ក្នុងសតវត្សរ៍ទី២១នេះ ការសិក្សាពេញមួយជីវិតបានក្លាយជាប្រធានបទដ៏សំខាន់សម្រាប់ការអប់រំ ហើយក៏ជាឧបករណ៍ដែលមានប្រយោជន៍សម្រាប់ទទួលបានសិទ្ធិសេរីភាព ភាពសប្បាយរីករាយ និងឆ្លើយតបនឹងបម្រែបម្រួលនៃតម្រូវការទីផ្សារការងារ ពិសេសភាពចាំបាច់នៃការសិក្សារបស់ពលរដ្ឋនៅគ្រប់កាលៈទេសៈ។ ការសិក្សាពេញមួយជីវិត បានក្លាយជាសមាសភាគសំខាន់ក្នុងគោលដៅទី៤ នៃក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ ពោលគឺធានាឱ្យការអប់រំមានគុណភាព បរិយាបន្ន សមធម៌ និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ស្របតាមការវិវត្តនៃវិស័យអប់រំក្នុងតំបន់ និងលើពិភពលោក។

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាកំពុងបោះជំហានទៅរកដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍ គឺប្រែក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ដោយត្រូវវុញ្ញប្រានតាមរយៈកម្លាំងពលកម្មដែលមានចំណេះដឹងបច្ចេកទេសកម្រិតខ្ពស់ បំណិនអប្បវត្ត និងផលិតភាពការងារ។ ទន្ទឹមគ្នានេះ ដើម្បីឱ្យគោលដៅទី៤ នៃក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ អាចសម្រេចបានពេញលេញ រាជរដ្ឋាភិបាលតាមរយៈក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកំណែទម្រង់វិស័យអប់រំតាមគ្រប់រូបភាព និងដាក់ចេញនូវគោលនយោបាយអប់រំផ្តោតលើសមាសភាគ៥ គឺ គុណធម៌ សមធម៌ បរិយាបន្ន អប់រំពេញមួយជីវិត និង សម្រាប់ទាំងអស់គ្នា។ ក្នុងន័យនេះ គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត ត្រូវបានរៀបចំឡើង ដោយមានចក្ខុវិស័យអភិវឌ្ឍធនធានមនុស្សប្រកបដោយសក្តានុពល ដើម្បីរួមចំណែកបង្កើនសេដ្ឋកិច្ចជាតិ និងលើកកម្ពស់សុខដុមជីវិតបុគ្គល គ្រួសារ និងសង្គម។

**៣-បញ្ហាផ្សេងៗ៖**

៣.១. អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានអនុម័តបញ្ជូន «កិច្ចព្រមព្រៀងស្តីពីវិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត» ទៅសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ។

៣.២. សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញនូវការសោកស្តាយយ៉ាងខ្លាំងចំពោះខ្លឹមសារដែល ឯ.ឧ.នាយករដ្ឋមន្ត្រីសិង្ហបុរី លី ស៊ានឡុង បានបង្ហោះតាមទំព័រហ្វេសប៊ុក កាលពីថ្ងៃទី៣១ ខែឧសភា កន្លងទៅ ដោយបានលើកឡើងថា «ពេលដែលគាត់ (ឧត្តមសេនីយ៍ ព្រេម) ធ្វើជានាយករដ្ឋមន្ត្រី (ថៃ) គាប់ជួននឹងពេលដែលសមាជិក ASEAN (កាលនោះយើងមាន៥ប្រទេស) រួមគ្នាប្រឆាំងការឈ្លានពានរបស់វៀតណាមមកលើកម្ពុជា និងប្រឆាំងរដ្ឋាភិបាលកម្ពុជាដែលបានជំនួសខ្មែរក្រហម។...» ។ ការលើកឡើងនេះបង្ហាញថា កាលនោះសិង្ហបុរីបានគាំទ្ររបបប្រល័យពូជសាសន៍ និងចង់ឲ្យរបបប្រល័យពូជសាសន៍វិលត្រឡប់មកកម្ពុជាវិញដែរ។ ជាក់ស្តែង សិង្ហបុរីបានធ្វើជាម្ចាស់ផ្ទះរៀបចំការប្រជុំដែលនាំដល់ការបង្កើតរដ្ឋាភិបាលចំរុះត្រីភាគី កម្ពុជាប្រជាធិបតេយ្យ និងអូសបន្លាយសង្គ្រាមនៅកម្ពុជា និងទុក្ខវេទនារបស់ប្រជាជនកម្ពុជា ជាង១០ឆ្នាំថែមទៀត ហើយដែលស្មើនឹងការប្រឆាំងនឹងការរស់ឡើងវិញរបស់ប្រជាជនកម្ពុជាផងដែរ។ ការលើកឡើងនេះជាការប្រមាថដល់ពលិកម្មសាច់ស្រស់ឈាមស្រស់របស់កងទ័ពស្ម័គ្រចិត្តវៀតណាម ដែលបានជួយរំដោះកម្ពុជាឲ្យរួចផុតពីរបបប្រល័យពូជសាសន៍។ ការលើកឡើងរបស់ ឯ.ឧ. លី ស៊ានឡុង នាពេលនេះក៏បានបង្ហាញដល់ប្រជាជនសិង្ហបុរីនិងពិភពលោកឱ្យឃើញថា មេដឹកនាំសិង្ហបុរីនាពេលនោះបានរួមចំណែកសម្លាប់ប្រជាជនកម្ពុជាយ៉ាងពិតប្រាកដ។ សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានចោទជាសំនួរទៅ ឯ.ឧ. នាយករដ្ឋមន្ត្រីសិង្ហបុរី លី ស៊ានឡុង ថាតើ ឯ.ឧ. ចាត់ទុកការកាត់ទោសមេដឹកនាំខ្មែរក្រហមកន្លងទៅនេះ ថាជាការត្រឹមត្រូវដែរឬអត់?

៣.៣. សម្តេចតេជោនាយករដ្ឋមន្ត្រី បានអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់ទូទាំងប្រទេស នាំគ្នាទទួលទាននំបញ្ចុក និងរៀបចំនំបញ្ចុកប្រគេនព្រះសង្ឃនៅតាមវត្តអារាម ក្នុងស្មារតីរួបរួមសាមគ្គីភាពនិងឯកភាពជាតិ ក្រោមម្លប់នៃសន្តិភាព ដែលជាចលនាជំរុញការប្រើប្រាស់និងលើកស្ទួយផលិតផលក្នុងស្រុក ពិសេសថែរក្សាអត្តសញ្ញាណជាតិឱ្យបានឋិតថេរគង់វង្សរៀងរហូតទៅ។ សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានអំពាវនាវដល់ម្ចាស់ផ្ទះជួលឱ្យកម្មករ កម្មការិនីស្នាក់នៅ រៀបចំនំបញ្ចុកសម្រាប់ពួកគេទទួលទាននៅថ្ងៃទី៩ ខែមិថុនា ខាងមុខនេះ ដើម្បីបង្ហាញពីសាមគ្គីភាពរវាងម្ចាស់ផ្ទះជួលនិងអ្នកជួលផ្ទះ និងបានលើកទឹកចិត្តឱ្យម្ចាស់រោងចក្ររៀបចំពិធីទទួលទាននំបញ្ចុកសម្រាប់កម្មករ កម្មការិនីដែលឈប់សម្រាកនៅថ្ងៃអាទិត្យខាងមុខផងដែរ។

៣.៤. សម្តេចតេជោនាយករដ្ឋមន្ត្រី បានដាក់បទបញ្ជា និងព្រមានដកបុណ្យសក្តិចោល ព្រមទាំងនាំខ្លួនយកទៅកាត់ទោសតាមផ្លូវច្បាប់ ចំពោះជនទាំងឡាយណាដែលពួកែខាងបាញ់បោះសេរី។

៣.៥. សម្តេចតេជោនាយករដ្ឋមន្ត្រី បានផ្តាំផ្ញើសាកសួរសុខទុក្ខដល់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលកំពុងឈរជើងតាមខ្សែបន្ទាត់ព្រំដែន និងបណ្តាកោះតាមសមុទ្រកម្ពុជា ដែលបាននិងកំពុងខិតខំថែរក្សាការពារសន្តិភាពនិងបូរណភាពទឹកដីជាតិមាតុភូមិ និងបានណែនាំឱ្យក្រុមការងារចុះចែកអាវភ្លៀងនៅរដូវវស្សា និងអាវរងានៅរដូវរងាជូនដល់កងទ័ព នគរបាល និងកងរាជអាវុធហត្ថដែលកំពុងឈរជើងនៅតាមព្រំដែន និងតាមអង្គភាពនានាឱ្យទាន់ពេលវេលា។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១២ និង៧នាទី។

ថ្ងៃសុក្រ ៥កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៩